# សុន្ទរកថា

# សម្តេចក្រឡាហោម ស ខេង

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## ក្នុងពិធីបើកវេទិកាស្តីពីភាពជាដៃគូរវាងរាជរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិល

ថ្ងៃព្រហស្បត្តិ៍ ១២កើត ខែបុស្ស ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៩

-------

- **គណៈអធិបតី**
- **ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី ជាសមាជិក សមាជិកា នៃអង្គវេទិកាទាំងមូល ជាទីមេត្រី!**

ថ្ងៃនេះខ្ញុំមានសេចក្តីសោមនស្សរីករាយយ៉ាងក្រៃលែង ដោយបានមកចូលរួមជាមួយនឹង ឯកឧត្តម លោកជំទាវ លោក លោកស្រី ដែលអញ្ជើញមកពីក្រសួង ស្ថាប័នពាក់ព័ន្ធរបស់រាជរដ្ឋាភិបាល អង្គការសង្គមស៊ីវិល និងដៃគូអភិវឌ្ឍន៍នានា ក្នុងពិធីបើកវេទិកាស្តីពីភាពជាដៃគូរវាងរាជរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិលនាឱកាសដ៏ថ្លៃថ្លានេះ។

ឆ្លៀតក្នុងឱកាសដ៏វិសេសវិសាលនេះ ក្នុងនាមរាជរដ្ឋាភិបាល ក្រសួងមហាផ្ទៃ និងក្នុងនាមខ្លួនខ្ញុំផ្ទាល់ ខ្ញុំសូមសំដែងនូវអំណរគុណយ៉ាងជ្រាលជ្រៅចំពោះវត្តមានរបស់គណៈអធិបតី ភ្ញៀវកិត្តិយស សមាជិក សមាជិកានៃអង្គវេទិកាទាំងមូលដែលបានឆ្លៀតពេលវេលាដ៏មមាញឹក ដើម្បីចូលរួមក្នុងវេទិកានាពេលនេះ។ ទន្ទឹមនេះ ខ្ញុំសូមថ្លែងអំណរគុណចំពោះអង្គការគណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា "អង្គការCCC" ដែលបានសហការក្នុងការរៀបចំវេទិកាស្តីពីភាពជាដៃគូរវាងរាជរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិលលើកទី២ នាថ្ងៃនេះ។ វេទិកាស្តីពីភាពជាដៃគូរវាងរាជរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិលលើកទី១ ត្រូវបានរៀបចំឡើងនៅថ្ងៃទី ២១ ខែមិថុនា ឆ្នាំ២០១៨ នៅក្នុងពេលវេលាមួយ ដែលព្រះរាជាណាចក្រកម្ពុជា កំពុងមមាញឹកក្នុងការត្រៀមរៀបចំការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី ៦ នាថ្ងៃទី ២៩ ខែកក្កដា ឆ្នាំ ២០១៨។

ជាដំបូងនេះ អនុញ្ញាតឱ្យខ្ញុំគូសបញ្ជាក់នូវអត្ថន័យនៃពាក្យ "ភាពជាដៃគូ" ថាតើមានន័យយ៉ាងដូចម្តេច?

នៅទីនេះ "ភាពជាដៃគូ" គឺសំដៅទៅលើទំនាក់ទំនងប្រកបដោយភាពស្មោះត្រង់រវាងរាជរដ្ឋាភិបាល រដ្ឋបាលថ្នាក់ក្រោមជាតិ និងអង្គការសង្គមស៊ីវិល ក្នុងការធ្វើសកម្មភាពអ្វីមួយសម្រាប់

បម្រើផលប្រយោជន៍សង្គម។ ជារួម ការអនុវត្តការងារក្នុងលក្ខណៈភាពជាដៃគូ អាចទទួលជោគជ័យបាន លុះត្រាតែភាគីជាដៃគូនឹងគ្នាឧស្សាហ៍ទាក់ទងគ្នាក្នុងការដោះស្រាយបញ្ហាអ្វីមួយជាមួយគ្នាដោយភាពស្មោះត្រង់ និងឥតលាក់លៀមរវាងគ្នា។ ភាគីជាដៃគូនឹងគ្នា ត្រូវមានការទុកចិត្តគ្នា គោរពគ្នា គាំទ្រគ្នាទៅវិញទៅមក និងយោគយល់អធ្យាស្រ័យគ្នា ព្រមទាំងរៀនសូត្រ និងចែករំលែកបទពិសោធន៍រវាងគ្នា ដើម្បីសម្រេចបាននូវគោលបំណងរួមណាមួយ។

- **ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី ជាទីមេត្រី!**

យោងតាមមាត្រា ៥១ថ្មី នៃរដ្ឋធម្មនុញ្ញ ឆ្នាំ១៩៩៣ ព្រះរាជាណាចក្រកម្ពុជាអនុវត្តនូវរបបនយោបាយប្រជាធិបតេយ្យ សេរីពហុបក្ស។ នៅក្នុងសង្គមប្រជាធិបតេយ្យ មានតួអង្គសំខាន់ៗចំនួនពីរ ដែលមិនអាចខ្វះបាន គឺគណបក្សនយោបាយ និងអង្គការសង្គមស៊ីវិល។

ផ្អែកលើមូលដ្ឋានខាងលើនេះ កម្ពុជាបានរៀបចំដំណើរការបោះឆ្នោតទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ យ៉ាងទៀងទាត់ ដើម្បីធានាឱ្យប្រជាពលរដ្ឋប្រើប្រាស់សិទ្ធិក្នុងការសំដែងនូវឆន្ទៈរបស់ខ្លួនក្នុងការជ្រើសរើសមេដឹកនាំដែលខ្លួនពេញចិត្ត ដោយសេរី ត្រឹមត្រូវ តម្លាភាព និងជឿទុកចិត្តបាន។ ជាពិសេស ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ កាលពីថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៨ កន្លងទៅនេះ បានប្រព្រឹត្តទៅដោយលក្ខណៈសេរី ត្រឹមត្រូវ និងមានសុវត្ថិភាពយ៉ាងល្អប្រសើរ។ ការបោះឆ្នោតនេះ មានគណបក្សនយោបាយចំនួន២០ បានចូលរួមប្រកួតប្រជែង និងមានប្រជា-ពលរដ្ឋដែលមានឈ្មោះក្នុងបញ្ជីបោះឆ្នោតចំនួន៨៣,០២% បានចេញទៅបោះឆ្នោត ដោយគ្មានការបង្ខិតបង្ខំ និងគំរាមកំហែង។ ការសម្រេចបាននូវការបោះឆ្នោតមួយប្រកបដោយជោគជ័យបានធ្វើឱ្យកម្ពុជាយើងកាន់តែមានភាពរឹងមាំថែមទៀតក្នុងការដឹកនាំគ្រប់គ្រងប្រទេសលើមាគ៌ាប្រជាធិបតេយ្យ។ បរិយាកាសនេះ ធ្វើឲ្យព្រះរាជាណាចក្រកម្ពុជាទទួលបាននូវសុខសន្តិភាព ស្ថិរភាពសន្តិសុខនិងសណ្តាប់ធ្នាប់សង្គមល្អ បានបង្កលក្ខណសម្បត្តិឱ្យប្រជាពលរដ្ឋយើងរួមកម្លាំងគ្នាសម្រេចបាននូវសមិទ្ធផលជាច្រើនក្នុងដំណើរកសាងជាតិ និងលើកកម្ពស់ជីវភាពរស់នៅរបស់ខ្លួនដែលបានចូលរួមចំណែកធ្វើឱ្យកម្ពុជាធានារក្សាបានកំណើនសេដ្ឋកិច្ចខ្ពស់ក្នុងរង្វង់ ៧,១% នៅក្នុងឆ្នាំ២០១៨។ រាជរដ្ឋាភិបាលកម្ពុជាក៏បានទទួលស្គាល់ផងដែរថា ការរីកចម្រើន និងការអភិវឌ្ឍហូតដល់ពេលនេះ គឺពិតជាមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធ ក្នុងនោះមានដៃគូអភិវឌ្ឍន៍ វិស័យឯកជន និងអង្គការសង្គមស៊ីវិល។ អង្គការសង្គមស៊ីវិលទាំងក្នុងស្រុក និងបរទេសបានដើរតួនាទីយ៉ាងសំខាន់ក្នុងការផ្តល់ និងគាំទ្រដល់សេវាសង្គមនៅតាមមូលដ្ឋានជនបទ និងសហគមន៍ដាច់ស្រយ៉ាល និងធ្វើសកម្មភាពនៅគ្រប់រាជធានី ខេត្តក្នុងវិស័យសំខាន់ៗដែលពាក់ព័ន្ធនឹងសេដ្ឋកិច្ចសង្គម នៅក្នុងប្រទេសកម្ពុជា។ អង្គការសង្គមស៊ីវិល ក៏បានចូលរួមផងដែរក្នុងការតស៊ូមតិឲ្យមាន

កំណែទម្រង់ជាតិ ដើម្បីលើកកម្ពស់សុខភាព ការអប់រំ អភិបាលកិច្ច សិទ្ធិមនុស្ស ប្រព័ន្ធយុត្តិធម៌ ច្បាប់ សេវាសង្គម បរិស្ថាន សុខុមាលភាពស្ត្រី និងកុមារ។

រាជរដ្ឋាភិបាលនីតិកាលទី៦ នៃរដ្ឋសភា ដែលកើតចេញពីការបោះឆ្នោតកាលពីថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៨ បានដាក់ចេញនូវយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ ដោយបានធ្វើការពង្រឹងពង្រីកនូវវិសាលភាព សម្រិតសម្រាំងបន្ថែម និងធ្វើអាទិភាវូបនីយកម្មមុំនីមួយៗនៃចតុកោណទាំង៤ ព្រមទាំងកែលម្អរបៀបវារៈគោលនយោបាយ និងយន្តការអនុវត្តមួយចំនួនឱ្យកាន់តែប្រសើរឡើងថែមទៀត ដើម្បីកសាងមូលដ្ឋានគ្រឹះចាំបាច់ទាំងឡាយក្នុងចក្ខុវិស័យដោយប្រែក្លាយកម្ពុជាពីប្រទេសដែលមានចំណូលមធ្យមកម្រិតទាប ទៅជាប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ ព្រមទាំងនាំប្រទេសជាតិយើងឆ្ពោះទៅកាន់ឋានៈជាប្រទេសដែលមានចំណូលខ្ពស់នៅឆ្នាំ២០៥០ ខាងមុខ។ ទន្ទឹមនេះ រាជរដ្ឋាភិបាល បានបើកទូលាយនូវកិច្ចសន្ទនាដ៏ស្មោះសសំដៅប្រមែប្រមូលនូវគំនិតបញ្ញា ព្រមទាំងធនធានមនុស្សពីគ្រប់ប្រភព ដោយគ្មានការរើសអើង ឬបែងចែកបក្សពួក តាមរយៈការបង្កើត "ឧត្តមក្រុមប្រឹក្សាពិគ្រោះ និងផ្តល់យោបល់" ដែលមានការចូលរួមពីគណបក្សនយោបាយចំនួន១៦ នៅក្នុងចំណោមគណបក្សនយោបាយចំនួន២០ ដែលបានចូលរួមប្រកួតប្រជែងក្នុងការបោះឆ្នោតជាតិលើកទី៦ កន្លងមកនេះ។ ជាមួយគ្នានេះដែរ រាជរដ្ឋាភិបាលក៏បានដាក់ចេញនូវសារាចរស្តីពីការរៀបចំឱ្យមានការពិគ្រោះយោបល់ក្នុងដំណើរការតាក់តែងក្របខណ្ឌគោលនយោបាយ និងច្បាប់នានា ដោយអនុញ្ញាតឱ្យមានការចូលរួមពីតំណាងគណបក្សនយោបាយនានាដែលបានចុះបញ្ជីស្របច្បាប់ អង្គការសង្គមស៊ីវិល និងផ្នែកឯកជនដែលមានការពាក់ព័ន្ធ។

គិតមកត្រឹមដំណាច់ឆ្នាំ២០១៨នេះ មានសមាគម និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកដែលបានតម្កល់សំណុំឯកសារ និងចុះបញ្ជីមានចំនួនសរុប **៥.៥២៣** ក្នុងនោះមានសមាគមចំនួន **២.២៩៧** និងអង្គការមិនមែនរដ្ឋាភិបាលចំនួន**៣.២២៦**។ ក្នុងឆ្នាំ២០១៨ កន្លងមកមានសមាគម និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក បានសុំចុះបញ្ជីនៅក្រសួងមហាផ្ទៃ ស្របតាមច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល មានចំនួន***សរុប២៨៩*** ក្នុងនោះមានសមាគមចំនួន**១៨០** និងអង្គការមិនមែនរដ្ឋាភិបាលមាន**ចំនួន១០៩។** ទន្ទឹមនេះ ខ្ញុំសូមជម្រាបជូនអង្គវេទិកាជ្រាបថា អគ្គនាយកដ្ឋានរដ្ឋបាល នៃក្រសួងមហាផ្ទៃ បានធ្វើកិច្ចសហការជាមួយអង្គការគណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា (CCC) ដើម្បីធ្វើជំរឿនសមាគម និងអង្គការមិនមែនរដ្ឋាភិបាល និងសិក្សាអំពីការរួមវិភាគទានក្នុងការអភិវឌ្ឍសង្គមកម្ពុជា ក្នុងគោលបំណងកំណត់ចំនួនជាក់លាក់នៃសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ព្រមទាំងប៉ាន់ប្រមាណពីធនធានចូលរួមរបស់សមាគម និងអង្គការមិនមែនរដ្ឋាភិបាល ក្នុងការអភិវឌ្ឍសង្គមកម្ពុជាផងដែរ។

តាមតួលេខខាងលើបង្ហាញថា ការបង្កើតសមាគម និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក មិនមានការថយចុះ ដូចការព្រួយបារម្ភពីបុគ្គលមួយចំនួនដែលជាញឹកញាប់តែងតែចោទប្រកាន់ រាជរដ្ឋាភិបាលកម្ពុជា និងក្រសួងមហាផ្ទៃ ពីការដាក់កំហិតលើសិទ្ធិសេរីភាពក្នុងការបង្កើតសមាគម និងអង្គការមិនមែនរដ្ឋាភិបាល រួមទាំងសិទ្ធិសេរីភាពនៃការបញ្ចេញមតិ និងយោបល់នោះឡើយ។ ដើម្បីលើកកម្ពស់កិច្ចសហប្រតិបត្តិការរវាងរាជរដ្ឋាភិបាល និងសមាគម និងអង្គការមិនមែនរដ្ឋា-ភិបាល កាលពី**ថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៨** កន្លងទៅ ក្រសួងមហាផ្ទៃបានរៀបចំវេទិកាស្តីពីភាពជាដៃគូរវាងរាជរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិល ដើម្បីពិនិត្យឡើងវិញនូវស្ថានភាពកិច្ចសហប្រតិបត្តិការរវាងភាគីទាំងពីរ។

ផ្អែកលើលទ្ធផលនៃវេទិកាលើកទី១ ខាងលើ រាជរដ្ឋាភិបាលបានបង្កើតក្រុមការងារអន្តរ-ក្រសួងមួយដែលមានតំណាងមកពីក្រសួង ស្ថាប័នពាក់ព័ន្ធ តាមរយៈសេចក្តីសម្រេចលេខ៨៤ សសរ ចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១៨ សម្រាប់ធ្វើការសិក្សាជាមួយអង្គការសង្គមស៊ីវិល សំដៅឲ្យមានការស្រុះស្រួលគ្នាក្នុងការអនុវត្តច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល និងច្បាប់នានាដែលពាក់ព័ន្ធនឹងអង្គការសង្គមស៊ីវិល ស្របតាមវិធានច្បាប់ និងនីតិវិធីជាធរមាន។ ក្រុមការងារអន្តរក្រសួងដើម្បីសម្របសម្រួលដោះស្រាយសំណើ និងសំណូមពររបស់អង្គការសង្គមស៊ីវិល បានរៀបចំកិច្ចប្រជុំលើកដំបូងរបស់ខ្លួន កាលពីថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០១៨ ដើម្បីត្រៀមរៀបចំវេទិកាស្តីពីភាពជាដៃគូរវាងរាជរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិល លើកទី២ នាថ្ងៃនេះ។

បច្ចុប្បន្ន សមាគម និងអង្គការមិនមែនរដ្ឋាភិបាលទាំងនេះ រួមទាំងសហគមន៍នានានៅមូលដ្ឋាន មានសិទ្ធិសេរីភាពពេញលេញក្នុងការធ្វើសកម្មភាពស្របតាមច្បាប់ធរមាន ដោយគ្មានការហាមឃាត់ ឬរារាំង ហើយមិនតម្រូវឱ្យជូនដំណឹងជាមុនក្នុងរយៈពេលយ៉ាងតិច៣ថ្ងៃទៅអាជ្ញាធរមូលដ្ឋានឡើយ។ ក្រសួងមហាផ្ទៃបានដាក់វិធានការឲ្យធ្វើការពិនិត្យ តាមដានលើការអនុវត្តគោលការណ៍ខាងលើនេះ ពីគ្រប់អាជ្ញាធរមូលដ្ឋាន។ រហូតមកដល់ដំណាច់ឆ្នាំ២០១៨ កន្លងទៅនេះ ក្រសួងមហាផ្ទៃមិនបានទទួលរបាយការណ៍ ឬព័ត៌មានណាមួយពាក់ព័ន្ធនឹងការរារាំងសកម្មភាពរបស់សមាគម អង្គការមិនមែនរដ្ឋាភិបាល និងសហគមន៍នានានៅមូលដ្ឋាននោះឡើយ។

ដើម្បីបង្ហាញនូវឆន្ទៈពង្រឹងលទ្ធិប្រជាធិបតេយ្យ នីតិរដ្ឋ និងលំហនយោបាយនៅកម្ពុជា រាជរដ្ឋាភិបាលតាមរយៈក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិបានចេញនូវសេចក្តីថ្លែងការណ៍ចុះថ្ងៃទី ០៣ ខែធ្នូ ឆ្នាំ២០១៨ ដោយផ្តោតលើចំណុចសំខាន់ៗចំនួន ០៤ ដូចខាងក្រោម៖

១.ការលើកកម្ពស់លទ្ធិប្រជាធិបតេយ្យ និងនីតិរដ្ឋបន្ថែមទៀត ជាពិសេសអនុញ្ញាតឱ្យបុគ្គលដែលជាប់បម្រាមធ្វើសកម្មភាពនយោបាយ អាចចាប់ផ្តើមធ្វើសកម្មភាពនយោបាយវិញបាន។

២.ការលើកកម្ពស់ភាពជាដៃគូពិតប្រាកដជាមួយអង្គការសង្គមស៊ីវិល។

៣.វិធានការដោះស្រាយពាក់ព័ន្ធសិទ្ធិការងារ និងសហជីព។

៤.ការលើកតម្កើងសិទ្ធិសេរីភាពសារព័ត៌មាននិងសេរីភាពបញ្ចេញមតិស្របតាមរដ្ឋធម្មនុញ្ញ និងច្បាប់នានាជាធរមាន។

- **ឯកឧត្តម លោកជំទាវ លោក លោកស្រី និងអង្គវេទិកាទាំងមូលជាទីមេត្រី!**

ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា ក្រសួងមហាផ្ទៃ និងក្នុងនាមខ្លួនខ្ញុំផ្ទាល់ ខ្ញុំសូមអំពាវនាវដល់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរមូលដ្ឋាន ត្រូវសម្របសម្រួល និងបង្កលក្ខណៈងាយស្រួលដល់អង្គការសង្គមស៊ីវិល ដែលបានចុះបញ្ជីត្រឹមត្រូវនៅក្រសួងមហាផ្ទៃ ព្រមទាំងសមាគម និងអង្គការមិនមែនរដ្ឋាភិបាលបរទេស ដែលបានចុះអនុស្សរណៈនៅក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ក្នុងការធ្វើសកម្មភាពដោយសេរី គ្មានការគំរាមកំហែង និងមិនលំអៀងស្របតាមច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានាជាធរមាន។ ទន្ទឹមនេះខ្ញុំសូមស្នើ ឯកឧត្តម លោកជំទាវ លោក លោកស្រី ដែលជាតំណាងដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល បន្តផ្តល់ការគាំទ្រ និងចូលរួមជាមួយរាជរដ្ឋាភិបាលកម្ពុជាក្នុងការលើកកម្ពស់លទ្ធិប្រជាធិបតេយ្យ និងការអភិវឌ្ឍសេដ្ឋកិច្ចជាតិឲ្យកាន់តែមានភាពរីកចម្រើន និងរុងរឿង ដូចបណ្តាប្រទេសនានាលើសកលលោក ។

ជាថ្មីម្តងទៀត ក្នុងនាមរាជរដ្ឋាភិបាល ក្រសួងមហាផ្ទៃ និងក្នុងនាមខ្លួនខ្ញុំផ្ទាល់ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិលទាំងអស់ ដែលបានចូលរួមចំណែកយ៉ាងសកម្មជាមួយរាជរដ្ឋាភិបាលកម្ពុជាកន្លងមក ដោយបានផ្តល់នូវការគាំទ្រទាំងផ្នែកហិរញ្ញវត្ថុ និងជំនួយបច្ចេកទេសជាច្រើន ក្នុងកិច្ចការអភិវឌ្ឍន៍នៅព្រះរាជាណាចក្រកម្ពុជា។

ជាទីបញ្ចប់ ខ្ញុំសូមប្រសិទ្ធពរជ័យជូន ឯកឧត្តម លោកជំទាវ លោក លោកស្រី សមាជិក សមាជិកា នៃអង្គវេទិកាទាំងមូល ក្នុងឱកាសឆ្នាំថ្មីឆ្នាំសកល ២០១៩ សូមជួបប្រទះតែនឹងព្រះពុទ្ធពរទាំងបួនប្រការ គឺអាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ និងសូមប្រកាសបើកវេទិកាស្តីពីភាពជាដៃគូរវាងរាជរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិល លើកទី២ ចាប់ពីពេលនេះតទៅ។

*សូមអរគុណ!*